សហភាពអឺរ៉ុប

actionaid

# បទបង្ហាញសង្ខេបថ្នាក់គោលនយោបាយក្នុងវិស័យជលផល ប្រៀបធៀបជាមួយ គោលការណ៍ណែនាំ ដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និងព្រៃឈើ" ភាពស្របគ្នា គម្លាត បញ្ហាប្រឈមសំខាន់ៗ និង ផ្លូវឆ្ពោះទៅមុខ"

*ដោយមេធាវី សេក សោភ័ណ (១៧ ធ្នូ ២០១៨)*

*បទបង្ហាញសង្ខេបថ្នាក់គោលនយោបាយនេះឈរលើមូលដ្ឋាននៃរបាយការណ៍ស្តីពី " ការពិនិត្យឡើងវិញនូវច្បាប់និងក្របខណ្ឌកម្ពុជាលើវិស័យដី ជលផល និងព្រៃឈើ ប្រៀបធៀបជាមួយ គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដី ជលផល និងព្រៃឈើ "ភាពស្របគ្នា គម្លាត បញ្ហាប្រឈមសំខាន់ ៗ និង ផ្លូវឆ្ពោះទៅមុខ" អង្គការ ActionAid & NGO Forum on Cambodia, ខែវិច្ឆិកា ឆ្នាំ ២០១៨ ។*

ច្បាប់ស្តីជលផលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា មានវិសាលភាពអនុវត្តលើរាល់ដែននេសាទទាំងអស់ដែលកំណត់ក្នុងជំពូក ៣ នៃច្បាប់នេះ ហើយក៏ចែងថា រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវធនធានជលផលនៅក្នុងដែននេសាទក្នុងទូទាំងប្រទេសកម្ពុជា។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិក៏បានធានាសិទ្ធិទាំងនេះដែរ ក៏ប៉ុន្តែបែងចែកឲ្យក្រសួងបរិស្ថានជាអ្នកកាន់អាណត្តិលើតំបន់ការពារធម្មជាតិ។ ធនធានជលផល ត្រូវបានអនុញ្ញាតឲ្យធ្វើការនេសាទជាលក្ខណៈគ្រួសារនៅគ្រប់ពេលវេលា និងដែននេសាទ ដោយប្រើឧបករណ៍នេសាទលក្ខណៈគ្រួសារ។

ទោះជាយ៉ាងណាក៏ដោយ មិនឃើញមានការចេញលិខិតឬ បែបបទរដ្ឋបាលបញ្ជាក់ជាលាយលក្ខណ៍អក្សរថា ការធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនោះត្រូវធានាដោយរបៀបណាដល់គ្រួសារ ដែលមានមុខរបរនេសាទជាប្រពៃណី រួមទាំងសហគមន៍ជនជាតិដើមភាគតិច ឬ ធានាតាមយន្តការរដ្ឋបាល

អ្វីនោះឡើយ តែមានសៀវភៅនាវានេសាទ។ រដ្ឋបាលជលផល ត្រូវបានផ្តល់អាណត្តិទទួលខុសត្រូវស្ថិតក្រោមក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ មានលិខិតបទដ្ឋានឲ្យមានការបង្កើតសហគមន៍នេសាទរួមទាំងការកំណត់កន្លែងនេសាទសហគមន៍ផង។

គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវ លើការកាន់កាប់ដី ជលផល និងព្រៃឈើ ហៅកាត់ខ្លីថា វីជីជីធី (VGGT) កំណត់អំពី "សិទ្ធិធម្មានុរូបនៃការកាន់កាប់ដែននេសាទ" ថា នៅពេលធ្វើច្បាប់ គោលនយោបាយ លិខិតបទដ្ឋានជាតិ រដ្ឋត្រូវគោរពដោយ

១) កំណត់អត្តសញ្ញាណអ្នកកាន់កាប់ធម្មានុរូបដោយធ្វើការកត់ត្រាក្នុងបញ្ជី

២) ការពារសិទ្ធិធម្មានុរូបរបស់ អ្នកកាន់កាប់សិទ្ធិ

៣) សម្របសម្រួលឲ្យអ្នកកាន់កាប់ធម្មានុរូប ដោយមិនមានការបន្ទុចបង្អាក់

៤) ក្នុងករណីមានការបំពានសិទ្ធិធម្មានុរូបលើជលផលនោះ រដ្ឋមានយន្តការប្រកបដោយប្រសិទ្ធភាពឲ្យម្ចាស់សិទ្ធិធម្មានុរូបរកយុត្តិធម៌តាមច្បាប់ រួចពីការគម្រាមកំហែង ឬ អំពើពុករលួយទាំងឡាយ។

ក្របខណ្ឌគតិយុត្តជាធរមានមិនចែងច្បាស់អំពី "សិទ្ធិធម្មានុរូបលើដែនជលផល ឬជលផល" នៃអ្នកកាន់កាប់សិទ្ធិប្រើប្រាស់ដូចមានក្នុង VGGT និងមិនមានការចុះបញ្ជីសិទ្ធិប្រើប្រាស់ ឬសិទ្ធិអាស្រ័យផលលើជលផលទេ ហើយក៏មិនមានលិខិតសម្គាល់អ្វីមួយចេញឲ្យអ្នកកាន់កាប់សិទ្ធិធម្មានុរូបទេ។ ប្រសិនបើសិទ្ធិប្រើប្រាស់ជាប្រពៃណីក្នុងដែនជលផលនោះត្រូវបានប៉ះពាល់ ដកហូត ឬបំពាន ក៏មិនមានយន្តការសម្រាប់ម្ចាស់សិទ្ធិទៅរកដំណោះស្រាយរឿងសិទ្ធិធម្មានុរូបលើជលផលក៏ទេដែរ គឺមានតែយន្តការសហគមន៍នេសាទ ដែលមានកិច្ចព្រមព្រៀងជាមួយរដ្ឋបាលជលផល ដែលកិច្ចព្រម ព្រៀងមានរយៈពេល ៣ ឆ្នាំ អាចបន្តបាន។ រដ្ឋមន្ត្រីក្រសួងកសិកម្ម អាចលុបចោលនូវកិច្ចព្រមព្រៀង នោះបានសម្រាប់ប្រយោជន៍សាធារណៈ។

នៅពេលមានការតតាំងគ្នារវាងភ្នាក់ងាររដ្ឋបាលជលផល និងអ្នកកាន់កាប់សិទ្ធិធម្មានុរូប ដែលធ្លាប់នេសាទ និងពឹងផ្អែកជីវភាពក្នុងដែននេសាទនោះ បញ្ហាគន្លឹះថាតើសិទ្ធិប្រពៃណីក្នុងការនេសាទក្នុងដែននេសាទ ដែលធានាដោយច្បាប់ត្រូវដោះស្រាយយ៉ាងណា? មានឯកសារអ្វីសម្គាល់សិទ្ធិប្រពៃណីដែលធ្លាប់តែមាន? តាមយន្តការអ្វី? ជារួម ដើម្បីរដ្ឋក្លាយជាកម្មសិទ្ធិករលើដែននេសាទ ក៏ត្រូវមានប័ណ្ណកម្មសិទ្ធិលើទ្រព្យ ដែលជាដែននេសាទគ្រប់ប្រភេទទាំងអស់តាមច្បាប់ដែរ មុននឹងត្រូវបានប្រគល់សិទ្ធិរបស់រដ្ឋទៅឲ្យរូបវន្ត ឬនីតិបុគ្គលអភិវឌ្ឍក្នុងរយៈពេលកំណត់មួយតាមកិច្ចសន្យា។ នៅក្នុង VGGT ចែងថាពលរដ្ឋក្នុងមូលដ្ឋានក៏មានសិទ្ធិធម្មានុរូបលើដែននេសាទនោះដែរ ដោយការ កាន់កាប់ដែនជាប្រពៃណី ហើយស្នើឲ្យរដ្ឋ គួរមានយន្តការធ្វើអត្តសញ្ញាណម្ចាស់សិទ្ធិ កត់ត្រាម្ចាស់សិទ្ធិ ការពារ និងសម្រួលដល់ម្ចាស់សិទ្ធិធម្មានុរូបទាំងនោះ។

នៅក្នុងក្របខណ្ឌគតិយុត្តជាធរមានអំពីអភិបាលកិច្ចល្អក្នុងវិស័យជលផល រដ្ឋគួរៈ

១- ពិចារណាពីការកំណត់អត្តសញ្ញាណ និងកត់ត្រាជាផ្លូវការនូវអត្តសញ្ញាណពលរដ្ឋដែលរស់នៅ ក្នុង ឬជិតដែននេសាទ និងកត់ត្រាក្នុងបញ្ជីនូវដែននេសាទ ឬបឹង ត្រពាំង ស្រះ ទន្លេ អូរ ។ល។ ដោយទទួលស្គាល់ ការពារ និងសម្របសម្រួលឲ្យពលរដ្ឋនោះដឹងឮថាមានការចុះបញ្ជី និងការទទួលស្គាល់សិទ្ធិធម្មានុរូបក្នុងទីតាំងនោះ។ ឧទាហរណ៍ថា បឹង ត្រពាំង ដែននេសាទ ឬដែនព្រៃលិចទឹកត្រូវបាន កំណត់ និងចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋ តែទីតាំងទាំងនោះក៏ត្រូវបានប្រើប្រាស់ជាយូរមកហើយសម្រាប់ការនេសាទជាមុខរបរសំខាន់ចិញ្ចឹមជីវិត។ ក្នុងន័យនេះ ពលរដ្ឋទាំងនេះមានទំនាក់ទំនង ជាមួយទីតាំង ព្រៃលិចទឹក បឹង ត្រពាំង ឬដែននេសាទនោះ ហើយនៅពេលត្រូវបានវិនិយោគនោះ សិទ្ធិប្រពៃណីដែល ធ្លាប់ មានក្នុងតំបន់នោះនឹងប៉ះពាល់ ដូច្នេះគួរមានការការពារគោរព និងដោះ ស្រាយតាមច្បាប់។ ក្នុង ន័យនេះ VGGT កំណត់ថា ពលរដ្ឋមានសិទ្ធិធម្មានុរូប និងការកាន់កាប់ធម្មានុរូបលើតំបន់នោះដែរ។

២- មានសេចក្តីណែនាំ ឬប្រកាសណាមួយដើម្បីឲ្យអាជ្ញាធរមូលដ្ឋានបញ្ជាក់ ឬចេញលិខិតបញ្ជាក់ សិទ្ធិធម្មានុរូបក្នុងដែននេសាទបន្ថែមលើកិច្ចការសហគមន៍នេសាទ ឬអ្នកដែលមិនមែនជាសមាជិកសហគមន៍នេសាទ តែជាអ្នកមានមុខរបរប្រពៃណីជាអ្នកនេសាទ និងសហការជាមួយពលរដ្ឋមូលដ្ឋាន ទាំងនោះក្នុងការធ្វើការកំណត់ទីតាំង ឬដែននេសាទដូចមានចែងក្នុងជំពូក ៣ នៃច្បាប់ស្តីពីជលផលដូច ជាការចុះបញ្ជីការដែននេសាទដែរ។

៣- មានយន្តការពិគ្រោះយោបល់ និងចូលរួមសម្រេចចិត្ត ដែលធានាថា ពលរដ្ឋជាម្ចាស់សិទ្ធិធម្មានុរូប បានចូលរួមដោយសេរី មានព័ត៌មាន និងយល់ស្របជាមុន មុននឹងរដ្ឋសម្រេចប្រគល់សិទ្ធិរបស់រដ្ឋក្នុងដែននេសាទឲ្យទៅរូបវន្ត ឬនីតិបុគ្គលក្នុងគោលបំណងផលប្រយោជន៍សាធារណៈ។

៤- ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងតួអង្គសំខាន់ៗឲ្យយល់ច្បាស់អំពីសិទ្ធិធម្មានុរូបក្នុងដែននេសាទ ពិសេសតំបន់សហគមន៍ជនជាតិដើមភាគតិច ដែលធ្លាប់ធ្វើនេសាទជាប្រពៃណីនៅក្នុងត្រពាំង បឹង អូរ ស្ទឹង ទន្លេ សមុទ្រ ដែលដែននេសាទទាំងអស់ស្ថិតនៅ។

៥- អប់រំផ្សព្វផ្សាយ បង្កើនការយល់ដឹងអំពីនីតិវិធីដាក់ពាក្យបណ្តឹង ការប្រមូលភស្តុតាងនៅពេលមាន ការរំលោភសិទ្ធិប្រពៃណីលើដែននេសាទ និងជលផល ដែលធានាដោយច្បាប់។

៦- ពិភាក្សាក្នុងក្របខណ្ឌថ្នាក់ជាតិលើការកំណត់យកគោលការណ៍ស្ទួលរបស់ វីជីជីធី ជាមូលដ្ឋាន។

គាំទ្រមូលនិធិដោយ

សហភាពអឺរ៉ុប

សហការរៀបចំដោយ៖

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

Building Community Voices

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

C.W.D.C.C

actionaid